**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សូមគោរពជូន**

**ឯកឧត្តម សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែល **ឯកឧត្តម** ត្រូវបានសមាជិក សមាជិកា នៃព្រឹទ្ធសភា បោះឆ្នោតជាឯកច្ឆន្ទជ្រើសរើស **ឯកឧត្តម** ជាប្រធានព្រឹទ្ធសភាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥។

ការបោះឆ្នោតជ្រើសរើស **ឯកឧត្តម** ជាប្រធានព្រឹទ្ធសភា ពិតជាសក្តិសមនឹងភាពចាស់ទុំនយោបាយរបស់ **ឯកឧត្តម** ដែលខ្ញុំមានជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **ឯកឧត្តម** ស្ថាប័នព្រឹទ្ធសភានឹងបន្តដំណើរការដោយរលូន និងទទួលបានជោគជ័យថ្មីៗ ថែមទៀត ដើម្បីរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំសូមប្រសិទ្ធិពរជូន **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**